មាត្រា ២ .- ចំណាយពាក់ព័ន្ធក្នុងមាត្រា១ ខាងលើត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ [illegible] [illegible] ។

មាត្រា ៣.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨
នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២
ហត្ថលេខា និង
អ៊ុង ហួត ហ៊ុន សែន

បានយកសេចក្តីគោរពជូនឯកឧត្តមនិងសម្តេចនាយករដ្ឋមន្ត្រី
ដើម្បីចុះហត្ថលេខា
[illegible]
គាត ឈន់
ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការពិសេស [illegible]
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

* * *

អនុក្រឹត្យ លេខ ៥៩ អនក្រ.បក
ស្តីពីការប្រើប្រាស់គណនីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ សំរាប់ហិរញ្ញប្បទាន នៃ វិនិយោគសាធារណៈ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៥/៥៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៥៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឲ្យប្រើ ដោយព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤

-បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ០៧/នស/៩៣ ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ១៩៩៣

-បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១/នស/ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៩៤

-បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ ជស/រកម/០១៩៨/០១ ចុះថ្ងៃទី ០៩ ខែមករា ឆ្នាំ ១៩៩៨

-បានឃើញសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលលេខ ០១ សប្រក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពីរបបអន្តរនីតិកម្មគណនេយ្យសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីបែបបទ អន្តរនីតិកម្មគណនេយ្យសាធារណៈ

-តាមសំណើររបស់ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សំរេច

មាត្រា ១.- ត្រូវបានអនុញ្ញាតឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បញ្ឈប់ដំណើរការ របបអន្តរនីតិកម្ម គណនេយ្យសាធារណៈដែលត្រូវបានបង្កើតឡើងតាមមាត្រា៥៤នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ និងពង្រីកតាមមាត្រា១៥នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៨ សំរាប់ដំណោះស្រាយក្នុងការផ្តល់ហិរញ្ញប្បទានដល់និតិវិធីគណនេយ្យសាធារណៈ និងបើកដំណើរការគណនេយ្យសាធារណៈដោយហិរញ្ញប្បទានបណ្តោះអាសន្ន ព្រមទាំងដំណោះស្រាយជាមួយបេឡាររបស់រតនាគារ ។

មាត្រា ២.- ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងស្ថាប័នដែលពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ឹង ហួត ហ៊ុន សែន

បានយកសេចក្តីគោរពជូនឯកឧត្តមនិងសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

ហត្ថលេខានិងត្រា

គាត ឈន់

ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការពិសេសស្តារនិងអភិវឌ្ឍន៍

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

★★★